# ក្តីរំពឹងរបស់ ADM ចំពោះអ្នកផ្គត់ផ្គង់

ADM ទទួលស្គាល់ថា ភាពទំនាក់ទំនងដែលមានសុខភាពល្អជាមួយអ្នកផ្គត់ផ្គង់ គឺសំខាន់ចាំបាច់ចំពោះភាពជោគជ័យរបស់យើង និងខិតខំលើកតម្កើងភាពទំនាក់ទំនងធុរកិច្ចដែលផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ដោយផ្អែកលើស្តង់ដាក្រមសីលធម៌ខ្ពស់បំផុត។ យើងជ្រើសរើសអ្នកផ្គត់ផ្គង់របស់យើងដោយយកចិត្តទុកដាក់ ដើម្បីធានាឲ្យបានថា ពួកគេមានការប្តេជ្ញាដូចយើងចំពោះសុចរិតភាព។ ADM រំពឹងថាអ្នកផ្គត់ផ្គង់របស់ខ្លួននឹងធ្វើធុរកិច្ចដោយត្រឹមត្រូវ មានសីលធម៌ និងអនុលោមតាមច្បាប់និងបទបញ្ញត្តិដែលមានជាធរមានទាំងអស់ នៅគ្រប់ពេល។ បន្ថែមលើនេះ យើងរំពឹងថា អ្នកផ្គត់ផ្គង់ទាំងឡាយយល់ និងប្រតិបត្តិតាមគោលការណ៍ខាងក្រោមនេះ។

## សុចរិតភាពនៃការប្រកបធុរកិច្ច

- **ការប្រឆាំងនឹងការលាងលុយកខ្វក់** - ADM រំពឹងថា អ្នកផ្គត់ផ្គង់របស់ខ្លួននឹងអនុលោមតាមច្បាប់និងបទបញ្ញត្តិស្តីពីការប្រឆាំងការលាងលុយកខ្វក់ និងការប្រឆាំងហិរញ្ញប្បទានដល់ភេរវករ។ ដោយមានការជាប់ទាក់ទងជាមួយសកម្មភាពធុរកិច្ចទាំងឡាយដែលបានធ្វើជាមួយ ADM អ្នកផ្គត់ផ្គត់ទាំងអស់មិនត្រូវពាក់ព័ន្ធជាមួយសកម្មភាពណាមួយដែលនឹងប្រើ ADM ដើម្បីលាងលុយ ឬក៏ផ្តល់ហិរញ្ញប្បទានដល់ភេរវកម្មឡើយ។

- **សំណូក និង អំពើពុករលួយ** – ADM ហាមប្រាមអំពើពុករលួយគ្រប់ទម្រង់ ហើយរំពឹងថា អ្នកផ្គត់ផ្គង់របស់ខ្លួននឹងធ្វើដូចគ្នានេះ។ វាមានន័យថាថា អ្នកផ្គត់ផ្គង់ទាំងឡាយមិនត្រូវផ្តល់ឬទទួលសំណូក ប្រាក់សូកប៉ាន់ ឬការបង់ប្រាក់អសីលធម៌ណាមួយឡើយ នៅពេលប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល ឬជាមួយធុរកិច្ចដទៃទៀត។ គ្រប់ពេល អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវតែអនុលោមតាម ច្បាប់សហរដ្ឋអាមេរិកស្តីពីការអនុវត្តចំពោះអំពើពុករលួយនៅបរទេស ព្រមទាំងច្បាប់ប្រឆាំងអំពើពុករលួយទាំងអស់នៅក្នុងស្រុក ដែលហាមប្រាមសំណូកពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងរដ្ឋាភិបាល។ ADM តម្រូវឲ្យអ្នកផ្គត់ផ្គង់ទាំងអស់ចូលរួមក្នុងដំណើរការត្រួតពិនិត្យអំពីភាពត្រឹមត្រូវរបស់ខ្លួន មុនធ្វើការប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល ក្នុងនាមក្រុមហ៊ុន។

- **កំណត់ត្រាធុរកិច្ចនិងហិរញ្ញវត្ថុ** – អ្នកផ្គត់ផ្គង់ទាំងអស់ត្រូវបានរំពឹងថានឹងរក្សាសៀវភៅ កំណត់ត្រា និងគណនីហិរញ្ញវត្ថុដ៏សុក្រឹតពាក់ព័ន្ធនឹងធុរកិច្ចរបស់ខ្លួនជាមួយ ADM។ អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវតែរក្សាកំណត់ត្រាគណនេយ្យនៃការបង់ប្រាក់ទាំងអស់ (រួមទាំងអំណោយនានា អាហារផ្សេងៗ ការកម្សាន្ត ឬក៏អ្វីៗផ្សេងទៀតដែលមានតម្លៃ) ដែលបានធ្វើឡើងក្នុងនាម ADM ឬក៏ក្រៅពីប្រាក់ដែល ADM បានផ្តល់ឲ្យ។ អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវតែផ្តល់សំណៅចម្លងមួយច្បាប់នៃកំណត់ត្រាគណនេយ្យនេះជូន ADM នៅពេលស្នើសុំ។

- **អំណោយ អាហារ និងការកម្សាន្តពាក់ព័ន្ធនឹងធុរកិច្ច** – អ្នកផ្គត់ផ្គង់ទាំងឡាយគួរជៀសវាងការផ្តល់ឲ្យនិយោជិត ADM នូវអំណោយជាការធ្វើដំណើរ អាហាររឿយៗ ឬអំណោយដែលមានតម្លៃថ្លៃ។ អាហារធម្មតាពេលប្រកបធុរកិច្ច និងគ្រឿងលើកសរសើរតិចតួចដែលមានតម្លៃស្តួចស្តើង អាចអនុញ្ញាតឲ្យបាន។ យើងហាមប្រាមអំណោយជាសាច់ប្រាក់ ឬមានតម្លៃដូចសាច់ប្រាក់ ដូចជាបណ្ណអំណោយជាសាច់ប្រាក់ ជាដើម។

- **ទំនាស់ផលប្រយោជន៍** – និយោជិត ADM មិនត្រូវមានផលប្រយោជន៍ហិរញ្ញវត្ថុណាមួយ ឬក៏មានការរៀបចំការជួលឲ្យធ្វើការជាមួយនឹងអ្នកផ្គត់ផ្គង់ណាមួយ ដែលអាចបង្កជាទំនាស់ ឬទំនងជាបង្កទំនាស់ជាមួយនឹងកាតព្វកិច្ចរបស់និយោជិតក្នុងការអនុវត្តការងារ ដើម្បីជាប្រយោជន៍ល្អបំផុតរបស់ ADM ឡើយ។ បើនិយោជិតរបស់អ្នកផ្គត់ផ្គត់ម្នាក់ មានភាពទំនាក់ទំនងលក្ខណៈគ្រួសារ (ប្តីឬប្រពន្ធ កូន ឪពុកម្តាយ បងប្អូនបង្កើត ជីដូនជីតា ម្តាយក្មេកឬឪពុកក្មេក បងប្អូនប្រុសស្រីសាច់ថ្លៃ ចៅ ដៃគូរស់នៅជាមួយគ្នា) ជាមួយនឹងនិយោជិត ADM ណាម្នាក់ ឬក៏បើអ្នកផ្គត់ផ្គង់នោះមានភាពទំនាក់ទំនងបែបផ្សេងទៀតជាមួយនឹងនិយោជិត ADM ណាម្នាក់ ដែលអាចបង្ហាញពីទំនាស់ផលប្រយោជន៍ណាមួយ អ្នកផ្គត់ផ្គង់នោះត្រូវតែបង្ហាញប្រាប់ពីព័ត៌មាននោះដល់ ADM ឬត្រូវធានាថា និយោជិត ADM បានធ្វើដូច្នោះ។ មិត្តភាពរវាងអ្នកផ្គត់ផ្គង់ទាំងឡាយជាមួយនឹងនិយោជិត ADM គឺជៀសមិនរួចនោះទេ ហើយអាចអនុញ្ញាតឲ្យបាន ប៉ុន្តែមិនត្រូវប្រើវាដើម្បីជះឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការធ្វើធុរកិច្ចឡើយ។

- **ការការពារទិន្នន័យ** - អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវបានរំពឹងថានឹងរក្សាការពារព័ត៌មានសម្ងាត់របស់ ADM រួមទាំងទិន្នន័យផ្ទាល់ខ្លួននិងកម្មសិទ្ធិ ដើម្បីរក្សាភាពជាដៃគូដែលយើងមានទំនុកចិត្ត។ អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវតែអនុលោមតាមច្បាប់ការពារទិន្នន័យទាំងអស់ដែលមានជាធរមាន រួមទាំងការអនុវត្តកិច្ចព្រមព្រៀងអំពីការដំណើរការទិន្នន័យ ដែលតម្រូវឲ្យមានការជូនដំណឹងអំពីការបំពាន ការបណ្តុះបណ្តាលនិយោជិត វិធានការបច្ចេកទេសនិងការចាត់ចែងសមរម្យ ដែលបង្ការការចូលប្រើមិនសមស្រប ការបង្ហាញ ឬការបំផ្លិចបំផ្លាញ ជាដើម ក្នុងចំណោមតម្រូវការដទៃទៀត។ អ្នកផ្គត់ផ្គង់ទាំងឡាយមិនត្រូវចែករំលែកឬលក់ព័ត៌មានរបស់ ADM ឡើយ លុះណាតែបានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរ ហើយក៏មិនត្រូវចែករំលែកជាមួយ ADM នូវព័ត៌មានរបស់តតិយភាគីដោយមិនបានទទួលការអនុញ្ញាតដែរ។

- **សុវត្ថិភាព និងគុណភាពផលិតផល** – អ្នកផ្គត់ផ្គង់ត្រូវគោរពតាមសៀវភៅណែនាំគុណភាព និងសុវត្ថិភាពអាហារសកលរបស់ ADM និងបំពេញតម្រូវការច្បាប់ បទបញ្ជា និងលក្ខណៈបច្ចេកទេសដែលបានព្រមព្រៀងទាំងអស់ ព្រមទាំងតម្រូវការបន្ថែមណាមួយដែល ADM បានផ្សព្វផ្សាយ រួមទាំងតម្រូវការដែលផ្អែកលើតំបន់ ផលិតផល ឬតម្រូវការអតិថិជន។ តម្រូវការដែលតឹងរឹងបំផុតដែលអាចអនុវត្តបាននឹងត្រូវអនុវត្ត។

- **ចីរភាព** - យើងរំពឹងថា អ្នកផ្គត់ផ្គង់ទាំងអស់នឹងគោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍ចីរភាពរបស់ ADM រួមទាំង គោលការណ៍អំពីសិទ្ធិមនុស្ស និង គោលការណ៍អំពីការការពារព្រៃឈើ ជីវចម្រុះ និងសហគមន៍ ព្រមទាំងបទបញ្ញត្តិនានានៅក្នុងផ្នែកខាងក្រោម (លក្ខខណ្ឌពលកម្ម និង សិទ្ធិមនុស្ស; បរិស្ថាន និង សិទ្ធិដីធ្លី)។

- **ទណ្ឌកម្មលើការដួញដូរ** – ADM រំពឹងថា អ្នកផ្គត់ផ្គង់របស់ខ្លួននឹងអនុលោមតាមច្បាប់និងបទបញ្ញត្តិស្ដីពីទណ្ឌកម្មលើការដួញដូរដែលមានជាធរមាន នៅក្នុងប្រទេសដែលគេប្រកបធុរកិច្ច។ ដោយមានការជាប់ទាក់ទងជាមួយធុរកិច្ចដែលខ្លួនធ្វើជាមួយ ADM អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវតែវៀរចាកការពាក់ព័ន្ធនឹងប្រតិបត្តិការផ្សេងៗជាមួយនឹងភាគី ប្រទេស ឬតំបន់ដែលទទួលរងទណ្ឌកម្ម (លុះណាតែផ្នែកច្បាប់របស់ ADM បានផ្ដល់ការអនុញ្ញាតផ្សេងពីនេះ) ឬក៏ការប្រើភាគីមួយទៀតឲ្យធ្វើសកម្មភាពទាំងឡាយដែលមិនអាចធ្វើដោយផ្ទាល់ដោយស្របច្បាប់ ដោយសារការហាមប្រាមនៃទណ្ឌកម្មលើការដួញដូរ។

## លក្ខខណ្ឌពលកម្ម និង សិទ្ធិមនុស្ស

- **ប្រាក់ឈ្នួល** - និយោជិតគ្រប់រូបដែលស្ថិតក្នុងកន្លែងប្រតិបត្តិការរបស់អ្នកផ្គត់ផ្គង់ និងខ្សែបណ្ដាញផ្គត់ផ្គង់ ត្រូវទទួលការទូទាត់យោងតាមច្បាប់និងបទបញ្ញត្តិទាំងឡាយនៅក្នុងស្រុកដែលមានជាធរមាន រួមទាំងការទូទាត់ពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា និងប្រាក់ធ្វើការបន្ថែមម៉ោង។

- **អំពើទាសភាព និង ពលកម្មរបស់កុមារ – អំពើទាសភាព** - អ្នកផ្គត់ផ្គង់ត្រូវតែហាមប្រាមការប្រើពលកម្មដោយបង្ខំគ្រប់ទម្រង់ទាំងអស់ រួមទាំងពលកម្មសងបំណុល ពលកម្មជាប់លិខិតសន្យា និងពលកម្មរបស់កុមារ នៅក្នុងកន្លែងប្រតិបត្តិការនិងខ្សែបណ្ដាញផ្គត់ផ្គង់របស់ពួកគេ។ គេមិនត្រូវគិតថ្លៃសេវាពីនិយោជិតទាំងឡាយ ជាថ្នូរនឹងការជួលឲ្យធ្វើការងារ ឬក៏មានរបស់បញ្ចាំជាទម្រង់នៃការកាន់កាប់ប្រាក់កាស អត្តសញ្ញាណកម្ម ឬរបស់របរផ្ទាល់ខ្លួនដទៃទៀតឡើយ – ដោយគ្មានការយល់ព្រមពីអ្នកធ្វើការ – ជាលក្ខខណ្ឌនៃការជួលឲ្យធ្វើការងារ។ យើងនឹងមិនអត់ឱនឡើយចំពោះការប្រើទណ្ឌកម្មលើកាយ ការគំរាមប្រើអំពើហិង្សា ឬការរំលោភបំពានជាទម្រង់ផ្សេងទៀត។ **ពលកម្មរបស់កុមារ** – អ្នកផ្គត់ផ្គង់ត្រូវបានហាមឃាត់យ៉ាងដាក់ច្បាស់ចំពោះការប្រើពលកម្មរបស់កុមារ ដែលបានឲ្យអត្ថន័យថាជាការងារដែលអាចបង្កគ្រោះអន្តរាយដល់សុខភាព សុវត្ថិភាព ឬទឹកចិត្តរបស់កុមារ, ការងារដែលបង្អាក់រំខានដល់ការអប់រំចាំបាច់ខានមិនបាន ឬក៏ការងារដែលថាពួកគេនៅក្មេងពេក។ អ្នកធ្វើការគ្រប់រូបនៅក្នុងកន្លែងប្រតិបត្តិការនិងខ្សែបណ្ដាញផ្គត់ផ្គង់របស់ពួកគេ ត្រូវតែបំពេញតាមតម្រូវការអាយុអប្បបរមាដើម្បីធ្វើការងារ តាមការឲ្យអត្ថន័យរបស់ អនុសញ្ញា ILO 138 ព្រមទាំងច្បាប់និងបទបញ្ញត្តិក្នុងស្រុក ដែលមានជាធរមាន។

- **សុខភាព និង សុវត្ថិភាព** - អ្នកផ្គត់ផ្គង់ត្រូវផ្ដល់បរិស្ថានធ្វើការដែលមានសុវត្ថិភាពនិងសុខភាពល្អ ព្រមទាំងអនុលោមតាមច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធនឹងសុខភាពនិងសុវត្ថិភាពដែលមានជាធរមាន។ យើងតម្រូវឲ្យអ្នកធ្វើការទទួលបាននូវការផ្គត់ផ្គង់ប្រកបដោយអនាម័យស្អាតនិងសមរម្យ។ យើងនឹងមិនអត់ឱនឡើយចំពោះការបំពានលើកាយ ការបំពាននិងការបៀតបៀនលើផ្លូវភេទ និងការបំពានឬការបៀតបៀនជាទម្រង់ដទៃផ្សេងទៀត។

- **WASH (ទឹក ការរក្សាអនាម័យ និងភាពមានអនាម័យ)** - អ្នកផ្គត់ផ្គង់ត្រូវគោរពសិទ្ធិទទួលបានទឹកបរិភោគដែលមានសុវត្ថិភាពនិងស្អាត សម្រាប់ខ្សែបណ្ដាញផ្គត់ផ្គង់របស់ពួកគេ ព្រមទាំងសហគមន៍ដែលពួកគេធ្វើប្រតិបត្តិការ។ គេក៏ត្រូវគោរពផងដែរនូវសិទ្ធិទទួលបានការរក្សាអនាម័យ និងភាពមានអនាម័យត្រឹមត្រូវ។

- **ម៉ោងការងារ** - ម៉ោងការងារត្រូវតែស្របទៅតាមលក្ខខណ្ឌតម្រូវការនៃច្បាប់ និងកិច្ចព្រមព្រៀងចរចាជារួមទាំងឡាយ ដែលអនុវត្តនៅក្នុងទីកន្លែងនោះ។ ការងារបន្ថែមម៉ោងទាំងអស់ត្រូវតែធ្វើដោយស្ម័គ្រចិត្ត។ ម៉ោងការងារមិនត្រូវច្រើនហួសហេតុឡើយ ហើយអ្នកធ្វើការត្រូវទទួលបាននូវពេលវេលាសម្រាកសមស្រប។ យើងសូមឲ្យយោបល់ជាខ្លាំងថា ម៉ោងការងារ និងថ្ងៃឈប់សម្រាក ត្រូវតែស្របតាម ក្រមមូលដ្ឋាននៃ ETI។

- **សេរីភាពនៃការចូលរួមក្នុងសមាគម** - អ្នកផ្គត់ផ្គង់ត្រូវគោរពសិទ្ធិរបស់និយោជិតកម្មករក្នុងការចូលរួម បង្កើត ឬមិនចូលរួមក្នុងសហជីពពលកម្មមួយ ដោយគ្មានការភ័យខ្លាចលើការផ្លាញ់ផ្លាល់ ការបំភិតបំភ័យ ឬការរុកគួន។ នៅកន្លែងដែលសហជីពដែលច្បាប់បានទទួលស្គាល់តំណាងឲ្យនិយោជិតកម្មករ អ្នកផ្គត់ផ្គង់ត្រូវគាំទ្រដល់ការបង្កើតឲ្យមានការសន្ទនាចរចាដែលមានលក្ខណៈស្ថាបនាជាមួយនឹងអ្នកតំណាងដែលពួកគេបានជ្រើសរើសដោយសេរី។ អ្នកផ្គត់ផ្គង់ត្រូវមានការប្តេជ្ញាចំពោះការចរចាទាមទារដោយសុចរិតជាមួយនឹងអ្នកតំណាងនៃនិយោជិតកម្មកររបស់ពួកគេ។

- **ការរើសអើង** - មិនត្រូវមានការរើសអើងឡើយ ក្នុងការជួលឲ្យធ្វើការងារ ការទូទាត់ប្រាក់ឈ្នួល សិទ្ធិទទួលបានការបណ្តុះបណ្តាល ការឡើងឋានៈ ការបញ្ចប់ការងារ ឬការចូលនិវត្តន៍ ដោយផ្អែកលើជាតិសាសន៍ វណ្ណៈ ជាតិកំណើត សាសនា អាយុ ពិការភាព យេនឌ័រ ស្ថានភាពរៀបការ ទំនោរផ្លូវភេទ សមាជិកភាពក្នុងសហជីព ឬសម្ពន្ធភាពខាងនយោបាយ។

- **បណ្តឹងសាទុក្ខ** - អ្នកផ្គត់ផ្គង់ត្រូវមានទម្រង់ការនៃការប្តឹងសាទុក្ខជាស្រេចនៅនឹងកន្លែង ដើម្បីអនុញ្ញាតឲ្យអ្នកធ្វើការពាំនាំការព្រួយបារម្ភ ឬបញ្ហាពាក់ព័ន្ធនឹងការងារ ក្នុងលក្ខណៈអនាមិក ដើម្បីឲ្យថ្នាក់គ្រប់គ្រងចាប់អារម្មណ៍។

## បរិស្ថាន និង សិទ្ធិដីធ្លី

- **ផលប៉ះពាល់លើបរិស្ថាន** - អ្នកផ្គត់ផ្គង់ត្រូវអនុវត្តជំហានទាំងឡាយ ដើម្បីកាត់បន្ថយផលប៉ះពាល់របស់ខ្លួនទៅលើបរិស្ថានឲ្យនៅតិចបំផុត ហើយត្រូវធានាឲ្យបាននូវការអនុលោមរបស់ខ្លួនតាមច្បាប់និងបទបញ្ញត្តិដែលមានជាធរមាន នៅក្នុងប្រទេសនានាដែលខ្លួនធ្វើប្រតិបត្តិការ។ អ្នកផ្គត់ផ្គង់ទាំងឡាយត្រូវធានាឲ្យបានថា ពួកគេកំពុងត្រួតពិនិត្យការប្រើប្រាស់របស់ពួកគេលើធនធានធម្មជាតិ ព្រមទាំងការគ្រប់គ្រងរបស់ពួកគេលើសំណល់។

- **សិទ្ធិដីធ្លី** - អ្នកផ្គត់ផ្គង់ត្រូវគោរពសិទ្ធិកាន់កាប់ដីធ្លី ព្រមទាំងសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ក្នុងស្រុក ក្នុងការផ្តល់ឲ្យ ឬរក្សាទុកនូវការយល់ព្រមដោយបានទទួលព័ត៌មានជាមុននិងដោយសេរី (FPIC) របស់ពួកគេ ចំពោះការធ្វើប្រតិបត្តិការលើដីដែលពួកគេមានសិទ្ធិកាន់កាប់តាមច្បាប់ ឬតាមទំនៀមទម្លាប់។ អ្នកផ្គត់ផ្គង់ត្រូវគោរពសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ក្នុងស្រុក ចំពោះដីនិងធនធាន ដោយយោងទៅតាម សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។

- **ការធ្វើចំណាត់ការ** - ADM ឲ្យយោបល់អ្នកផ្គត់ផ្គង់លើកតម្កើងដំណោះស្រាយក្នុងការកាត់បន្ថយការប្រែប្រួលធាតុអាកាស និងការបំភាយចេញនូវឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងលើកតម្កើងការអភិរក្សលើធនធានទឹក និងជីវចម្រុះ ក្នុងផ្ទៃដីកសិកម្មតាមរយៈការគ្រប់គ្រងលើការប្រើប្រាស់ដីប្រកបដោយចីរភាព និងការអនុវត្តការស្តារប្រព័ន្ធបរិស្ថានធម្មជាតិមកវិញ ក្នុងតំបន់ដែលមានតម្លៃខ្ពស់ក្នុងការអភិរក្ស។

## អនុលោមភាព

- **ការស្វែងរកប្រភព និងសម្ភារៈ** - អ្នកផ្គត់ផ្គង់ត្រូវអនុលោមតាមសំណើទាំងឡាយសម្រាប់ប្រទេសសម្ភារៈនៃប្រភពដើមនៃទំនិញ និងសេវា ឬក៏យុទ្ធសាស្ត្រនៃភាពអាចតាមដានខ្សែបណ្តាញផ្គត់ផ្គង់។
- ***វនកម្ម*** - ADM សូមរក្សាសិទ្ធិក្នុងការស្នើសុំឲ្យធ្វើសវនកម្មដោយ ADM និង/ឬ តតិយភាគី ដើម្បីផ្ទៀងផ្ទាត់ភាពអនុលោមជាមួយក្តីរំពឹងទាំងនេះ។ សវនកម្មត្រូវផ្អែកលើការវិភាគចំពោះហានិភ័យ គំហើញពីមុន ឧបទ្ទវហេតុនៃការឃ្លាំមើល និងការចូលរួមទាក់ទងរបស់ភាគីពាក់ព័ន្ធ។
- **ពមិនអនុលោម** (ផលវិបាកនៃការប្រតិបត្តិខុស និងការខកខានក្នុងការបំពេញតាមក្តីរំពឹងរបស់ ADM ចំពោះអ្នកផ្គត់ផ្គង់) - ADM រំពឹងថា អ្នកផ្គត់ផ្គង់របស់ខ្លួននឹងអនុលោមទាំងស្រុងតាមច្បាប់ដែលមានជាធរមាន ព្រមទាំងប្រកាន់ខ្ជាប់តាមស្តង់ដាបរិស្ថាននិងសង្គមដែលទទួលស្គាល់ជាអន្តរជាតិ បន្ថែមលើក្រមប្រតិបត្តិ ព្រមទាំងគោលការណ៍របស់ខ្លួន។ យើងរំពឹងថាអ្នកផ្គត់ផ្គង់បានត្រួតពិនិត្យ ទម្រង់ការនៃការគ្រប់គ្រងការមិនអនុលោមរបស់អ្នកផ្គត់ផ្គង់ ដើម្បីយល់ដឹងឲ្យបានច្បាស់ថាតើ ADM នឹងចាត់ការដូចម្តេចចំពោះបញ្ហានៃការមិនអនុលោមតាម។
- ***រាយការណ៍អំពីការប្រតិបត្តិខុសដែលអាចកើតឡើង*** – អ្នកផ្គត់ផ្គង់អាចបញ្ជូនសំណួរ ឬរាយការណ៍ក្តីបារម្ភផ្សេងទៀតជូន ADM តាម លិខិតប្រៃសណីយ៍៖ P.O. Box 1470, Decatur, IL, USA 62525; អ៊ីមែល៖ compliance@adm.com; ឬ អនឡាញ៖ www.theadmwayhelpline.com. អ្នកអាចធ្វើការរាយការណ៍ដោយអនាមិក នៅកន្លែងដែលច្បាប់បានអនុញ្ញាត។ ក្រមប្រតិបត្តិរបស់ ADM ហាមប្រាមការសងសឹកចំពោះការរាយកាណ៍ដែលបានធ្វើឡើយដោយសុចរិត